# សំណួរ និងចម្លើយសុខភាពសម្រាប់ផលិតផល CoreTect®
# សម្រាប់ប្រើប្រាស់លើដើមក្រូចឆ្មារដើម្បីកម្ចាត់សត្វល្អិតក្រូចឆ្មារអាស៊ី

រៀបចំដោយ ការិយាល័យវាយតម្លៃគ្រោះថ្នាក់សុខភាពបរិស្ថាន, CalEPA

OEHHA
SCIENCE FOR A HEALTHY CALIFORNIA

**សំណួរ:** ***តើ CoreTect® ជាអ្វី?***

**ចម្លើយ:** Coretech® គឺជាផលិតផលថ្នាំសម្លាប់សត្វល្អិតដែលមានធាតុផ្សំអ៊ីមីដាក្លូព្រីតសកម្ម។ Corectech® ត្រូវបានប្រើប្រាស់ដោយនាយកដ្ឋានចំណីអាហារ និងកសិកម្មកាលីហ្វ័រញ៉ា (CDFA) ដើម្បីកំចាត់សត្វល្អិតស៊ីស្លឹកក្រូចឆ្មារអាស៊ី (ACP) គឺជាប្រភេទសត្វល្អិតដែលរាតត្បាតបង្កឲ្យមានជម្ងឺដល់ដំណាំ។ Corectech® អាចប្រើប្រាស់បានតាមរយៈការដាក់ថ្នាំពីរគ្រាប់ ២ - ៥ អ៊ីញ នៅពីក្រោមស្រទាប់ដីនៅក្បែរដើមក្រូចឆ្មារ។ ស្រោចទឹកនៅលើដីដែលលាយជាមួយគ្រាប់ថ្នាំ និងអនុញ្ញាតិឲ្យសារធាតុអ៊ីមីដាក្លូព្រីតជ្រាបចូលទៅកាន់ឬស និងបន្តចែករំលែកចូលទៅកាន់ដើមក្រូចឆ្មារ។ សត្វល្អិតខ្លាចសារធាតុអ៊ីមីដាក្លូព្រីតពេលវាប៉ះជាមួយសរសៃដំណាំ ឬលេបសារធាតុរាវរបស់រុក្ខជាតិចូលទៅក្នុងខ្លួនវា។

**សំណួរ:** ***តើសារធាតុផ្សំសកម្មអ៊ីមីដាក្លូព្រីតមានដំណើរការដូចម្តេច?***

**ចម្លើយ:** នៅពេលដែលសត្វល្អិតលេបវាចូល ឬប៉ះពាល់ជាមួយនឹងសារធាតុអ៊ីមីដាក្លូព្រីត វារុំជាប់ទៅជាមួយនឹងកោសិការសរសៃប្រសាទរបស់វា។ ការបញ្ជូនដ៏មានប្រសិទ្ធិភាពរបស់សរសៃប្រសាទបែបនេះធ្វើឲ្យមានសន្ទុះ និងបណ្តាលឲ្យមានរំញ័រ និងមានបញ្ហាជាមួយនឹងប្រព័ន្ធប្រសាទផ្សេងទៀត។ ប្រការបែបនេះនឹងធ្វើឲ្យសត្វល្អិតចង្រៃងាប់។ សារធាតុអ៊ីមីដាក្លូព្រីតមិនរុំជាប់ខ្លាំងទៅនឹងកោសិការប្រព័ន្ធប្រសាទប្រភេទសត្វចិញ្ចឹមកូនដោយទឹកដោះទេ ដែលធ្វើឲ្យវាមានសារធាតុពុលតិចប៉ះពាល់ដល់មនុស្ស និងប្រភេទសត្វផ្សេងៗទៀត។

**សំណួរ:** ***តើសារធាតុអ៊ីមីដាក្លូព្រីតប៉ះពាល់ដល់សុខភាពរបស់មនុស្សដែរឬទេ?***

**ចម្លើយ:** ការធ្វើតេស្តសាកល្បងបង្ហាញថាសារធាតុអ៊ីមីដាក្លូព្រីតបង្កជាផលប៉ះពាល់ដល់ប្រព័ន្ធប្រសាទ ថ្លើម ក្រពេញទីរ៉ូអ៊ីដ និងការឡើងទម្ងន់។ យ៉ាងណាមិញផលប៉ះពាល់ទាំងអស់នេះមិនត្រូវបានរំពឹងទុកថានឹងកើតមានឡើងនៅក្នុងកម្រិតបរិមាណសារធាតុអ៊ីមីដាក្លូព្រីតទាបទេដែលវាកើតឡើងនៅពេល CoreTech® ត្រូវបានប្រើប្រាស់ស្របតាមការណែនាំនៅលើសញ្ញាបង្ហាញ។ សារធាតុអ៊ីមីដាក្លូព្រីតមិនបណ្តាលឲ្យកើតមានជម្ងឺមហារីក ក្រហាយភ្នែក ឬកើតរមាស់នៅលើស្បែកទេ (អាលែកហ្ស៊ីប៉ះពាល់ការរលាកស្បែក)។

**សំណួរ:** ***តើភ្នាក់ងារបទបញ្ញត្តិផ្តល់ចំណាត់ថ្នាក់សារធាតុអ៊ីមីដាក្លូព្រីតមានផលប៉ះពាល់ និងមានហានិភ័យដល់សុខភាពដូចម្តេចខ្លះ?***

**ចម្លើយ:** សារធាតុអ៊ីមីដាក្លូព្រីតត្រូវបានដាក់ចំណាត់ថ្នាក់ដោយទីភ្នាក់ងារការពារបរិស្ថានអាមេរិកថាជា "ថ្នាំសម្លាប់សត្វល្អិតសម្រាប់ប្រើប្រាស់ទូទៅ"។ ក្នុងន័យនេះមានន័យថាមានផលិតផលដែលមានកម្រិតសារធាតុអ៊ីមីដាក្លូព្រីតសម្រាប់សារធារណៈជនទូទៅ។ ផលិតផលនេះរួមមានទាំងផលិតផលដែលបានចុះឈ្មោះសម្រាប់ប្រើប្រាស់នៅលើស្មៅ និងធ្វើឲ្យរុក្ខជាតិកាន់តែលូតលាស់ប្រសើរឡើង ព្រមទាំងអាហារជាច្រើនមុខ និងគ្រាប់ធុញ្ញជាតិសម្រាប់បរិភោគផង។ សារធាតុអ៊ីមីដាក្លូព្រីតក៏អាចប្រើប្រាស់បាននៅតាមអគារសម្រាប់កម្ចាត់សត្វកណ្តៀរ និងកម្ចាត់ចៃនៅលើសត្វឆ្មារ និងសត្វឆ្កែផងដែរ។

**សំណួរ:** ***តើមានអ្វីខ្លះដែលត្រូវបានគេស្គាល់ថាជាសារធាតុផ្សំគ្មានជីវិតនៅក្នុង CoreTect® ?***

**ចម្លើយ:** ចំពោះការសិក្សាស្រាវជ្រាវអំពីសត្វ សារធាតុផ្សំគ្មានជីវិតមួយចំនួននៅក្នុង CoreTech® បណ្ដាល ឲ្យប៉ះពាល់ដល់ស្បែក ឬក្រហាយភ្នែកខ្លះៗ នៅពេលដែលលាបពាយត្រង់កន្លែងដែលនៅខ្ពស់ឆ្ងាយជាងកន្លែងដែលមនុស្សអាចឈោងទៅដល់ពីការប្រើប្រាស់ CoreTech® ។ នៅពេលប្រើប្រាស់ស្រមតាមសេចក្ដីណែនាំ CoreTech® ត្រូវដាក់នៅផ្នែកខាងក្រោមស្រទាប់ដីដើម្បីធ្វើឲ្យប្រាកដថាមិនប៉ះពាល់ដល់មនុស្សចំពោះសារធាតុផ្សំគ្មានជីវិតរបស់វា។

**សំណួរ:** ***តើត្រូវការប្រុងប្រយ័ត្នអ្វីខ្លះដែលមនុស្សគួរធ្វើ<u>ពេល</u>ប្រើប្រាស់ CoreTech® នៅលើដីក្រោមដើមក្រូចឆ្មារក្រោយផ្ទះរបស់ពួកគេ ?***

**ចម្លើយ:** ដូចបានបញ្ជាក់ការប្រុងប្រយ័ត្ន មនុស្សម្នាក់ៗ និងសត្វត្រូវតែនៅក្នុងផ្ទះនៅពេលប្រើប្រាស់ថ្នាំ។ អ្នករស់នៅក្នុងលំនៅដ្ឋានមិនគួរធ្វើការងារក្រៅផ្ទះ ឬអនុញ្ញាតិឲ្យក្មេងៗ ឬសត្វចិញ្ចឹមលេងនៅជិតៗកន្លែងប្រើប្រាស់ថ្នាំថ្មីៗ។

**សំណួរ:** ***តើត្រូវការប្រុងប្រយ័ត្នអ្វីខ្លះដែលមនុស្សគួរធ្វើ<u>បន្ទាប់ពី</u>ប្រើប្រាស់ CoreTech® នៅលើដីក្រោមដើមក្រូចឆ្មារក្រោយផ្ទះរបស់ពួកគេ ?***

**ចម្លើយ:** អ្នករស់នៅក្នុងលំនៅដ្ឋានគួរជៀសវាងប៉ះពាល់ត្រង់កន្លែងប្រើប្រាស់ថ្នាំរហូតដល់វាស្ងួត។ សូមកុំឲ្យក្មេងៗ ឬសត្វចិញ្ចឹមកាយដីនៅក្បែរកន្លែងដែលប្រើប្រាស់ថ្នាំ។ ធ្វើតាមសេចក្ដីណែនាំដែលបានផ្ដល់ឲ្យដោយ CDFA។

**សំណួរ:** ***តើខ្ញុំអាចញ៉ាំផ្លែក្រូចឆ្មារដែលបានប្រើថ្នាំសម្លាប់សត្វល្អិត CoreTech® បានដែរឬទេ ?***

**ចម្លើយ:** បន្ទាប់ពីប្រើថ្នាំសម្រាប់សត្វល្អិត CoreTech® នៅលើដីក្បែរដើមក្រូចឆ្មាររួចហើយ សារធាតុអ៊ីមីដាក្លូព្រីតត្រូវបានស្រូបយកដោយឫសរុក្ខជាតិ ហើយវាអាចត្រូវបានរកឃើញនៅក្នុងផ្លែឈើ និងស្លឹករបស់វាដែលជាកន្លែងវាផ្ដល់នូវការគ្រប់គ្រងប្រឆាំងជាមួយនឹងសត្វល្អិត។ យ៉ាងណាមិញ កម្រិតដែលត្រូវបានគេរកឃើញមានសារធាតុអ៊ីមីដាក្លូព្រីតនៅក្នុងផ្នែកនៃដើមរុក្ខជាតិមានកម្រិតទាបខ្លាំងណាស់ ហើយការបរិភោគផ្លែវា ឬស្លឹករបស់វាមិនបានធ្វើឲ្យមានគ្រោះថ្នាក់ប៉ះពាល់ដល់សុខភាពរបស់មនុស្សទេ។

**សំណួរ:** ***តើមានផលិតផលផ្សេងទៀតនៅលើទីផ្សារដែលមានសារធាតុអ៊ីមីដាក្លូព្រីតដែរឬទេ ?***

**ចម្លើយ:** ផលិតផលថ្នាំសម្លាប់សត្វល្អិតផ្សេងៗទៀតដែលមានសារធាតុអ៊ីមីដាក្លូព្រីតដែលជាផលិតផលសម្លាប់ចៃ និងផលិតផលសម្រាប់សួនដំណាំនៅតាមផ្ទះ។

**សំណួរ:** ***តើខ្ញុំគួរធ្វើបែបណាបើខ្ញុំមានអារម្មណ៍ថាឈឺបន្ទាប់ពីប្រើប្រាស់ផលិតផល CoreTech® រួច ?***

**ចម្លើយ:** ហៅទៅកាន់ទូរស័ព្ទប្រព័ន្ធគ្រប់គ្រងសារធាតុពុលកាលីហ្វ័រញ៉ា តាមរយៈលេខ (៨០០) ២២២-១២២២ ឬទៅពិគ្រោះយោបល់ជាមួយគ្រូពេទ្យរបស់អ្នក។

---

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:
កម្មវិធីជម្ងឺវាតត្បាត
ការិយាល័យវាយតម្លៃគ្រោះថ្នាក់សុខភាពបរិស្ថាន
ទីភ្នាក់ងារការពារបរិស្ថានរដ្ឋកាលីហ្វ័រញ៉ា

1001 I Street, P.O. Box 4010
Sacramento, CA 95812
Phone: (916) 327-7319

1515 Clay Street, 16th Floor
Oakland, CA 94612
(510) 622-3170

អ៊ីម៉ែល: pesticides@oehha.ca.gov
ខែមិថុនា ឆ្នាំ២០១៨